California’s protection & advocacy system
*លេខទូរស័ព្ទហៅមិនអស់ប្រាក់ (800) 776-5746*

# ការទទួលបានឧបករណ៍បច្ចេកវិជ្ជាជំនួយ តាមរយៈ នាយកដ្ឋានសនីតិសម្បទា

*ខែកុម្ភៈ ឆ្នាំ 2016 ឯកសារបោះពុម្ពផ្សាយ លេខ 5584.06 - Cambodian*

## 1. តើ នាយកដ្ឋានសនីតិសម្បទា (DOR, Department of Rehabilitation) អាចផ្តល់ឲ្យខ្ញុំនូវឧបករណ៍បច្ចេកវិជ្ជាជំនួយដែរឬទេ (assistive technology)?

អាចផ្តល់ជូនបាន ។ ក្រមស្តានីតិសម្បទា (Rehabilitation Act) បានកំណត់និយមន័យចំពោះពាក្យថាឧបករណ៍បច្ចេកវិជ្ជាជំនួយជា “ការប្រើបច្ចេកវិជ្ជា វិស្វកម្ម ឬគោលការណ៍តាមបែបវិទ្យាសាស្ត្រ ដើម្បីផ្តល់ឲ្យចំពោះសេចក្តីត្រូវការ និងដោះស្រាយចំពោះឧបសគ្គរបស់ជនពិការក្នុងវិស័យជាអាទិ៍ ការអប់រំ ការស្តារនីតិសម្បទា ការប្រកបការងារ ការធ្វើដំណើរ ការរស់នៅដោយឯករាជ្យ និងការលំហែកាយ ។ 29 ក្រមសហរដ្ឋអាមេរិក (U.S.C., United States Code) វគ្គទី 705(30)

បច្ចេកវិជ្ជាស្តារនីតិសប្បទា ត្រូវបានចែកចេញជាបីប្រភេទ ៖ *វិស្វកម្មស្តារនីតិសម្បទា ឧបករណ៍បច្ចេកវិជ្ជាជំនួយ* និង *សេវាកម្មបច្ចេកវិជ្ជាជំនួយ* ។ បច្ចេកវិជ្ជាស្តានីតិសម្បទា ក៏រួមបញ្ចូលផងដែរនូវ ការកែតម្រូវយានយន្តទូរគមនាគមន៍ ភាពងាយរំញោច ព្រមទាំងជំនួយបច្ចេកវិជ្ជា និងឧបករណ៍ផ្សេងៗទៀត តែមិនបានរាប់បញ្ចូលការចៀវ និងការជួសជុលយានយន្តឡើយ ។ 9

ក្រមនិយតកម្មរដ្ឋកាលីហ្វ័រនីញ៉ា (CCR, California Code of Regulations) វគ្គទី 7024.7 ។

## 2. តើអ្វីជាឧបករណ៍ជំនួយបច្ចេកវិជ្ជា (assistive technology device)?

"ឧបករណ៍បច្ចេកវិជ្ជាជំនួយ" *គឺជាពាក្យដែលគេប្រើដើម្បីហៅឧបករណ៍ ឬប្រព័ន្ធណាមួយ សម្រាប់ជួយជនពិការក្នុងការធ្វើអ្វីមួយ ដែលគេមិនអាចធ្វើបានដោយគ្មានឧបករណ៍នោះទេ ឬដើម្បីបង្កើនភាពងាយស្រួល និងផ្តល់សុវត្ថិភាពក្នុងការធ្វើអ្វីមួយ ។* ឧបករណ៍ជំនួយប្រភេទនេះ អាចរកទិញបានពីហាងដែលគេបានកែសម្រួល ឬកែប្រែដើម្បីត្រូវទៅតាមតម្រូវការជាក់លាក់របស់អ្នក ។ 29 U.S.C. វគ្គទី 3001 *et seq.*, 9 CCR វគ្គទី 7002 ។

## 3. តើអ្វីជាសេវាកម្មបច្ចេកវិជ្ជាជំនួយ (assistive technology service)?

"សេវាកម្មបច្ចេកវិជ្ជាជំនួយ" គឺជាសេវាកម្មសម្រាប់ជួយអ្នកក្នុងការជ្រើសរើស ទិញ ឬប្រើឧបករណ៍បច្ចេកវិជ្ជាជំនួយ ដោយមានរួមបញ្ចូលនូវ ៖

- ការវាយតម្លៃអំពីតម្រូវការរបស់អ្នក បូករួមទាំងការវាយតម្លៃចលនារាងកាយរបស់អ្នក ចំពោះបរិស្ថានផ្ទាល់របស់អ្នក ។
- ការចៀវ ការជួល ឬការទិញ (ទទួលបាន) ឧបករណ៍បច្ចេកវិជ្ជាជំនួយ ។
- ការជ្រើសរើស ការរចនា ការធ្វើឲ្យប្រើបាន ការធ្វើឲ្យស្របតាមតម្រូវការជាលក្ខណៈបុគ្គល ការសម្របខ្លួនទៅតាមតម្រូវការ ការប្រើប្រាស់ ការថែរក្សា ការជួសជុល ឬការប្តូរឧបករណ៍បច្ចេកវិជ្ជាជំនួយ ។
- ការសម្របសម្រួល និងការប្រើការព្យាបាលផ្សេងៗ ការអន្តរាគមន៍ ឬសេវាកម្ម ជាមួយនឹងឧបករណ៍បច្ចេកវិជ្ជាជំនួយ ដូចជាអ្វីៗទាំងឡាយដែលពាក់ព័ន្ធនឹងផែនការតម្រូវជាលក្ខណៈបុគ្គលសម្រាប់ការធ្វើការ (IPE, Individualized Plan for Employment) បច្ចុប្បន្នរបស់អ្នក ។
- ជំនួយបណ្តុះបណ្តាល ឬជំនួយបច្ចេកវិជ្ជាដល់អ្នក ឬបើសិនជាសមរម្យ គឺសម្រាប់សមាជិកគ្រួសារអ្នក អាណាព្យាបាល អ្នកតស៊ូមតិ ឬអ្នកតំណាងស្របច្បាប់របស់អ្នក ។
- ជំនួយបណ្តុះបណ្តាល ឬជំនួយបច្ចេកទេសដល់អ្នកបម្រើការងារអាជីព (រួមបញ្ចូលបុគ្គលជាអ្នកផ្តល់សេវាកម្មអប់រំ និងសេវាកម្មស្តានីតិសម្បទា) និយោជក ឬអ្នកដទៃទៀតដែលជាអ្នកផ្តល់សេវាកម្ម និយោជក ឬបើមិនដូច្នោះទេ គឺជាអ្នកដែលចូលរួមយ៉ាងសំខាន់ក្នុងផ្នែកចម្បងដែល

ធ្វើឲ្យជីវិតរបស់អ្នកមានដំណើរការ ដែលជំនួយចំពោះការបណ្ដុះបណ្ដាល ឬជំនួយបច្ចេកទេស គឺមានសារៈសំខាន់ចំពោះអ្នក ដើម្បី អាចសម្រេច គោលបំណងការងារ ដូចអ្វីដែលបានសរសេរ និងបានយល់ព្រមនៅក្នុង ផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងាររបស់អ្នក ។

– U.S.C. វគ្គទី 3002 (5), 9 CCR វគ្គទី 7002.5 ។

## 4. តើ DOR អាចផ្ដល់ឲ្យខ្ញុំនូវឧបករណ៍ជំនួយបានដែរឬទេ នៅពេលខ្ញុំដាក់ពាក្យសុំសេវាកម្មពី DOR ននេះ?

អាចផ្ដល់ជូនបាន ។ DOR អាចផ្ដល់ជូនអ្នកនូវបច្ចេកវិជ្ជាជំនួយបាន នៅពេល គេកំណត់អំពីភាពមានសិទ្ធិទទួលសេវាកម្មពី DOR ននេះ របស់អ្នក ។ នៅពេល ព័ត៌មានដែលមានស្រាប់ មិនអាចកំណត់បាននូវកម្រិតនៃមុខងារ រាងកាយបច្ចុប្បន្នរបស់អ្នកបាន ឬថាយើងមិនមានព័ត៌មាន ប្រភេទនេះនៅក្នុងដៃទេ នោះDOR អាចរៀបចំធ្វើការវាយតម្លៃ គឺរួមបញ្ចូលការវាយតម្លៃពីតម្រូវការរបស់អ្នកចំពោះឧបករណ៍បច្ចេកវិជ្ជាជំនួយ និងសេវាកម្មបច្ចេកវិជ្ជាជំនួយ ក៏ដូចជាសេវាកម្មជំនួយផ្សេងៗទៀត ដែលមាន ភាពចាំបាច់សម្រាប់កំណត់អំពីភាពមានសិទ្ធិទទួលជំនួយរបស់អ្នក ។ 9 CCR 7062 (g)(1)(a)(B) ។

សម្រាប់ព័ត៌មានបន្ថែមអំពីភាពមានសិទ្ធិទទួលជំនួយពីDOR សូមអាន *សន្លឹកការពិតស្ដីអំពីភាពមានសិទ្ធិទទួលបានសេវាកម្មស្ដារនីតិសម្បទាវិជ្ជាជីវៈ (Eligibility for Vocational Rehabilitation Services Fact Sheet) ឯកសារបោះពុម្ពផ្សាយលេខ F066.01 តាមអាសយដ្ឋាន* [http://www.disabilityrightsca.org/pubs/F06601.pdf](http://www.disabilityrightsca.org/pubs/F06601.pdf)

នៅពេលដែលយើងខ្ញុំបានកំណត់ឃើញថា អ្នកមានសិទ្ធិទទួលសេវាកម្មហើយ DOR អាចដាក់បញ្ចូលបច្ចេកវិជ្ជាជំនួយទៅក្នុងផែនការតម្រូវជាលក្ខណៈបុគ្គលសម្រាប់ ការធ្វើការរបស់អ្នក នៅពេលដែលត្រូវការ ដើម្បីអាចសម្រេចបាននូវគោលបំណង ការងាររបស់អ្នក ។ 9 CCR វគ្គទី 7131 (a)(2)(A) ។

## 5. តើអ្វីជាវិស្វកម្មស្ដារនីតិសម្បទា (rehabilitation engineering)?

វិស្វកម្មស្ដារនីតិសម្បទា មានន័យថា ជាការប្រើប្រាស់នូវវិស្វកម្មវិទ្យាសាស្ត្រជាប្រព័ន្ធ ដើម្បីរៀបចំ បង្កើត សម្របការប្រើប្រាស់ សាកល្បងការប្រើប្រាស់ វាយតម្លៃ ដាក់ឲ្យ ប្រើប្រាស់ និងបែងចែកដំណោះស្រាយបច្ចេកវិជ្ជាចំពោះបញ្ហា ដែលជនពិការ ម្នាក់ៗកំពុងជួបប្រទះ ចំពោះវិស័យចលនារាងកាយ ដូចជាការរំកិលខ្លួន ការ

ទំនាក់ទំនង ការស្តាប់ ការមើល ការយល់ និងចំពោះសកម្មភាពពាក់ព័ន្ធនឹង ការធ្វើការ ការរស់នៅដោយឯករាជ្យ ការអប់រំ និងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ។ 29 U.S.C. 723 (a)(14) 9 CCR វគ្គទី 7024.4 ។

សេវាកម្មវិស្វកម្មស្ពានីតិសម្បទា មានជាអាទិ៍ ការវាយតម្លៃកន្លែងការងាររបស់ជនពិការ និងការស្វែងរកសមាសភាគដែលមានលក់នៅទីផ្សារ ដើម្បីបង្កើតស្ថានីការងារដែលអាចឲ្យអ្នកប្រើបាន ជាមួយនឹងកម្ពស់តុដែលអាចកែសម្រួលបាន និងការរៀបចំសម្ភារៈការិយាល័យឡើងវិញ ដូចជាម៉ាស៊ីនកុំព្យូទ័រ ម៉ាស៊ីនព្រីននិងម៉ាស៊ីនទូរសារ ។ ការសម្របខ្លួនប្រភេទនេះ ជាទូទៅគឺត្រូវបានធ្វើឡើង ដោយវិស្វករផ្នែកស្តានីតិសម្បទាដែលមានសមត្ថភាពគ្រប់គ្រាន់ ។

## 6. តើបច្ចេកវិជ្ជាស្តានីតិសម្បទាប្រភេទណាដែលអាចដាក់បញ្ចូលក្នុងផែនការតម្រូវជាលក្ខណៈបុគ្គលសម្រាប់ការធ្វើការរបស់ខ្ញុំ)?

បើអ្នកត្រូវការបច្ចេកវិជ្ជាស្តានីតិសម្បទា ដើម្បីសម្រេចបាននូវគោលបំណងការងាររបស់អ្នក នោះផែនការតម្រូវជាលក្ខណៈបុគ្គលសម្រាប់ការធ្វើការរបស់អ្នកត្រូវរួមបញ្ចូលនូវ ៖

- សេវាកម្មបច្ចេកវិជ្ជាស្តានីតិសម្បទាជាក់លាក់ដែលអ្នកត្រូវការ
- វិធីផ្តល់បច្ចេកវិជ្ជាដល់អ្នក នៅក្នុងស្ថានភាពដែលមានការរួមបញ្ចូលគ្នាច្រើនបំផុត និង
- នរណាជាអ្នកផ្តល់បច្ចេកវិជ្ជា និងសេវាកម្មនានាដែលពាក់ព័ន្ធនឹងការទិញ និងការប្រើប្រាស់ឧបករណ៍នេះ ។ 29 U.S.C. 722(b)(3)(B)(i)(I) ។

បទពិសោធន៍ការសាកល្បងការងារ និងបច្ចេកវិជ្ជាជំនួយ ។ “បទពិសោធន៍ការសាកល្បងការងារ” (TWE, Trial Work Experience) មានន័យថា ជាការរុករកលទ្ធភាព សមត្ថភាព និងភាពដែលអាចបំពេញការងារនៅក្នុងស្ថានភាពជាក់ស្តែងរបស់អ្នក ហើយវាត្រូវ *តែ*ធ្វើឡើង នៅមុនការកំណត់ថាតើអ្នកអាចទទួលបានផលប្រយោជន៍ពីសេវាកម្មស្តានីតិសម្បទាវិជ្ជាជីវៈដែរឬទេ ។ ជាផ្នែកមួយនៃបទពិសោធន៍ការសាកល្បងការងារDOR*ត្រូវតែ*ដាក់បញ្ចូលនូវសេវាកម្មដែលសមរម្យ ដែលមានជាអាទិ៍បច្ចេកវិជ្ជាជំនួយ និងសេវាកម្ម ដើម្បីសម្រួលដល់តម្រូវការស្តានីតិសម្បទារបស់អ្នក ក្នុងអំឡុងពេលទទួលបទពិសោធន៍ការសាកល្បងការងារ ។ 9 CCR វគ្គទី 7029.1 ។ (សម្រាប់ព័ត៌មានបន្ថែមអំពីភាពមានសិទ្ធិទទួលជំនួយពីDORស្តានីតិសម្បទា សូមអាន *សន្លឹកការពិតស្តីអំពីភាពមានសិទ្ធិទទួលសេវាកម្មស្តានីតិសម្បទាវិជ្ជាជីវៈ ឯកសារ*

*បោះពុម្ពផ្សាយលេខF066.01 [Eligibility for Vocational Rehabilitation Services Fact Sheet])*

## 7. ក្រៅពីបច្ចេកវិជ្ជាស្ពានីតិសម្បទា តើDORអាចផ្តល់អ្វីខ្លះទៀតដល់ខ្ញុំ?

DORក៏អាចផ្តល់ជូនអ្នកបានដែរនូវសេវាកម្មការធ្វើឲ្យស្ថានភាពរាងកាយ និងចិត្តមកកាន់សភាពដើមវិញ ។ សេវាកម្មទាំងនេះ មានផ្តល់ជូននៅពេលមានភាពចាំបាច់ ដើម្បីកែតម្រូវ ឬដើម្បីកែសម្រួលសំខាន់ៗ ចំពោះស្ថានភាពរាងកាយ ឬស្ថានភាពចិត្តដែលមានលំនឹង ឬមានការរីកចម្រើនយ៉ាងយឺតៗ នៅក្នុងចិរវេលាមួយដែលសមរម្យ ។ ជំនួយបែបនេះ មានរួមបញ្ចូលសេវាកម្មវេជ្ជសាស្ត្រច្រើនផ្នែក ។ ប្រភេទឧបករណ៍ និងសេវាកម្មដែលមានផ្តល់ជូនក្រោមជំនួយស្ថិតក្នុងប្រភេទនេះ មានៈ

- សរីរាង្គសិប្បនិម្មិត ឧបករណ៍ទប់អវយវ ឬឧបករណ៍ជំនួយដទៃទៀត ដែលមានសារៈសំខាន់ក្នុងការជួយឲ្យអ្នកអាចទទួលបាន ឬអាចរក្សាបានការងារមួយ
- វ៉ែនតា និងសេវាកម្មថែទាំភ្នែក
- ការព្យាបាលរាងកាយដោយចលនា
- ការព្យាបាលផ្លូវកាយនិងផ្លូវចិត្ត
- កៅអីកង់ និងឧបករណ៍ជំនួយការស្តាប់
- ការព្យាបាលរោគពិការភាពការនិយាយ និងការព្យាបាលបញ្ហាការស្តាប់ព្រមទាំង
- សេវាកម្មពិសេសដើម្បីព្យាបាលអ្នកជម្ងឺតម្រងនោមក្នុងដំណាក់កាលចុងក្រោយ រួមបញ្ចូលទាំងការផ្សាំសរីរាង្គ ការលាងឈាម ការដាក់ក្រលៀនសិប្បនិម្មិត និងការផ្គត់ផ្គង់លើការថែទាំជម្ងឺប្រភេទនេះ ។ 9 C.C.R. វគ្គទី 7020 ។

## 8. តើខ្ញុំត្រូវចេញការចំណាយចំពោះសេវាកម្មដែលផ្តល់ជូនដោយ DORដែរឬទេ?

ពេលខ្លះ ខាងDOR តម្រូវឲ្យអ្នកជួយចេញថ្លៃសេវាកម្មស្ពានីតិសម្បទាវិជ្ជាជីវៈដែលអ្នកត្រូវការ មានដូចជាថ្លៃឧបករណ៍បច្ចេកវិជ្ជាជំនួយ និងសេវាកម្មនានា ។ DOR នឹងពិចារណាអំពីប្រាក់ចំណូល និងធនធានងាយបង្វែជាសាច់ប្រាក់របស់អ្នក

ចំនួនសមាជិកក្នុងគ្រួសារអ្នក និងការលើកលែងចំពោះការចំណាយផ្នែកវេជ្ជសាស្ត្ររបស់អ្នក ដើម្បីគណនាអំពីចំនួនប្រាក់ដែលអ្នកត្រូវចូលរួមចេញលើការចំណាយ ។ 9 C.C.R. វគ្គទី 7190 ។

អ្នកមិនចាំបាច់ចេញការចំណាយឡើយ ប្រសិនបើអ្នកជាបុគ្គលដែលទទួលបានជំនួយសន្តិសុខសង្គមធានារ៉ាប់រងពិការភាព (SSDI, Social Security Disability Insurance) ប្រាក់ចំណូលសន្តិសុខបង្គ្រប់ (SSI, Supplemental Security Income)/ប្រាក់ជំនួយបង្គ្រប់របស់រដ្ឋ (SSP, State Supplementary Payment) និងជំនួយសាធារណៈផ្សេងទៀត ដូចជា ជំនួយសង្គ្រោះទូទៅ ឬជំនួយទូទៅ ឬជំនួយគ្រួសារដែលមានកូនក្នុងបន្ទុក (AFDC, Aid to Families with Dependent Children) (ឥឡូវគេហៅថាជំនួយបណ្ដោះអាសន្នដល់គ្រួសារតោកយ៉ាក [TANF - Temporary Assistance for Needy Families])

សេវាកម្មស្តារនីតិសម្បទាវិជ្ជាជីវៈដូចខាងក្រោម គឺមានផ្តល់ជូនដល់អតិថិជនរបស់ DOR ដោយឥតគិតថ្លៃអ្វីទាំងអស់ ៖

- ការវាយតម្លៃអំពីសក្តានុពលនៃការស្តារនីតិសម្បទា បូករួមទាំងការធ្វើរោគវិនិច្ឆ័យ និងសេវាកម្មនានាដែលពាក់ព័ន្ធ
- ការប្រឹក្សាយោបល់ ការផ្តល់មតិណែនាំ និងសេវាកម្មបញ្ជូនបន្ត
- ការរកកន្លែងឲ្យចូលធ្វើការ ឬជំនួយរកការងារឲ្យធ្វើ
- ការបណ្តុះបណ្តាល ការបង្វឹក សៀវភៅ និងសម្ភារៈផ្សេងៗទៀតសម្រាប់បណ្តុះបណ្តាល
- ឧបករណ៍ដែលចាំបាច់សម្រាប់បំពេញការងារ
- សេវាកម្មផ្ទាល់ខ្លួន ដូចជាសេវាអ្នកជួយថែទាំ អ្នកបកប្រែភាសាគ និងអ្នកបកប្រែភាសា អ្នកជួយកត់ត្រា អ្នកបើកបរ និងអ្នកជួយអាន
- ថ្លៃធ្វើដំណើរ ព្រមទាំង
- សេវាកម្មបង្រៀនធ្វើការ ។
- CCR វគ្គទី 7191 ។

## 9. តើមានពេលណាដែលDOR រំពឹងថាខ្ញុំនឹងអាចទទួលបានបច្ចេកវិជ្ជាស្តារនីតិសម្បទាពីប្រភពផ្សេងទៀតដែរឬទេ?

DOR នឹងមិនចេញថ្លៃការចំណាយលើរបស់ ឬសេវាកម្ម ដែលមានផ្តល់ជូនដោយប្រភពផ្សេងឡើយ (សេវាកម្មដែលអាចធៀបគ្នាបាន) ។ 29 U.S.C. វគ្គទី 721(a)(8)

។ ទោះជាយ៉ាងណាក៏ដោយ អ្នកមិនចាំបាច់ត្រូវប្រើអត្ថប្រយោជន៍ដែលអាចជៀបគ្នាបានទេ ប្រសិនបើការទទួលយកអត្ថប្រយោជន៍ទាំងអស់នោះវានាំឲ្យមានការបង្អាក់ ឬពន្យារការរីកចម្រើនក្នុងការសម្រេចបានលទ្ធផលការងារការរកកន្លែងឲ្យធ្វើការបន្ទាន់ ឬសេវាកម្មនានារបស់អ្នក ប្រសិនបើអ្នកស្ថិតក្នុងហានិភ័យវេជ្ជសាស្ត្រក្នុងកម្រិតខ្ពស់ ។ 34 ក្រមនិយត្តកម្មសហព័ន្ធ (C.F.R., Code of Federal Regulations) 361.53(a), 9 CCR 7198 ។ ដូចគ្នានេះដែរ សេវាកម្មដូចខាងក្រោមមិនតម្រូវឲ្យអ្នកទទួលពីប្រភពផ្សេងឡើយ ៖

- ការវាយតម្លៃអំពីសក្តានុពលនៃការស្តានីតិសម្បទា
- ការប្រឹក្សាយោបល់ ការផ្តល់មតិណែនាំ និងសេវាកម្មបញ្ជូនបន្ត
- សេវាកម្មបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងសេវាកម្មបណ្តុះបណ្តាលផ្សេងៗទៀត មានដូចជាការបណ្តុះបណ្តាលផ្ទាល់ខ្លួន និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបែបសម្រួល សៀវភៅ ឧបករណ៍ និងសម្ភារៈបណ្តុះបណ្តាលផ្សេងទៀត ដែលមានផ្តល់ជូនដោយប្រភពផ្សេងក្រៅពីវិជ្ជាស្ថានឧត្តមសិក្សា
- ការរកកន្លែងឲ្យធ្វើការ
- សេវាកម្មវិស្វកម្មស្តានីតិសម្បទា និង
- សេវាកម្មបង្រៀនធ្វើការ ។

9 CCR ញ៉ា វគ្គទី 7196 ។

សម្រាប់ព័ត៌មានបន្ថែមស្តីអំពីអត្ថប្រយោជន៍ដែលអាចជៀបគ្នាបាន សូមអាន *សន្លឹកការពិតស្តីអំពីសេវាកម្មស្តានីតិសម្បទា និងអត្ថប្រយោជន៍ដែលអាចជៀបគ្នាបាន ឯកសារបោះពុម្ពផ្សាយលេខ F065.01 តាមអាសយដ្ឋាន* http://www.disabilityrightsca.org/pubs/F06501.pdf

## 10. តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើDORបដិសេធសំណើសុំបច្ចេកវិជ្ជាស្តានីតិសម្បទារបស់ខ្ញុំ?

អ្នកអាចស្នើសុំឲ្យមានការពិនិត្យសំណើសុំរបស់អ្នកតាមបែបរដ្ឋបាល ឬស្នើសុំឲ្យមានការដោះស្រាយវិវាទ និង/ឬស្នើសុំឲ្យមានសវនាការយុត្តិធម៌ ។ 9 CCR វគ្គទី 7351(c), 7353.6 (b)-(c) និង 7354 ។

សម្រាប់ព័ត៌មានបន្ថែមស្តីអំពីការប្តឹងឧទ្ធរណ៍របស់DOR សូមអាន *សន្លឹកការពិតស្តីអំពីជម្រើស និងដំណើរការនៃការប្តឹងឧទ្ធរណ៍របស់DOR រដ្ឋកាលីហ្វ័រនីញ៉ា (California Department of Rehabilitation Appeals Options and Process Fact*

*Sheet) ឯកសារបោះពុម្ពផ្សាយលេខ* 5530.01 *តាមអាសយដ្ឋាន*
*http://www.disabilityrightsca.org/pubs/553001.pdf*

*Disability Rights California បានទទួលមូលនិធិឧបត្ថម្ភពីប្រភពផ្តល់ជំនួយនានាមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ* http://www.disabilityrightsca.org